# អង្គការកសិករនៅកម្ពុជា៖ តើបានជួយលើកកម្ពស់សន្តិសុខស្បៀងអ្នកក្រីក្រនៅជនបទដែរឬទេ?[១]

## សេចក្ដីផ្ដើម

តាមធម្មតាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប្រជាជនក្រីក្រភាគច្រើនតែងរស់នៅតាមតំបន់ជនបទ និងរកចិញ្ចឹមជីវិតជាចម្បងដោយការធ្វើកសិកម្មខ្នាតតូច។ សហគមន៍អ្នកផ្ដល់ជំនួយអន្តរជាតិ និងរដ្ឋាភិបាល បានទទួលស្គាល់ពីសារៈសំខាន់នៃកសិកម្មខ្នាតតូចនេះ ដូចមានបង្ហាញក្នុងការប្ដេជ្ញាចិត្តនានា ដើម្បីចាត់វិធានការដ៏ចាំបាច់ផ្សេងៗ សំដៅបង្កើន និងគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម និងកំណើនសេដ្ឋកិច្ចជនបទ។ គោលនយោបាយអន្តរាគមន៍ជាទូទៅបំផុត អនុម័តដោយប្រទេសកំពុងអភិវឌ្ឍន៍គឺត្រូវលើកកម្ពស់ការបង្កើតអង្គការផលិតករជនបទនានា (Bingen *et al.* 2003; Chirwa *et al.* 2005)។ កម្លាំងជំរុញចំបងសម្រាប់កិច្ចការនេះ គឺសេវាគាំទ្ររួម និងប្រកបដោយប្រសិទ្ធភាពដល់អ្នកធ្វើកសិកម្មខ្នាតតូច ដើម្បីកាត់បន្ថយឧបសគ្គធំៗដែលរារាំងដល់កំណើនផលិតភាព ព្រមទាំងការលើកកម្ពស់សមត្ថភាពជួយខ្លួនឯង និងអំណាចរួមគ្នាក្នុងការគ្រប់គ្រងទីផ្សារ (Barham & Chitemi 2009; Bachke 2010)។

នៅកម្ពុជា ប្រជាជនក្រីក្រជាង ៩០% រស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្មជាប្រភពជីវភាពចម្បង។ វិស័យកសិកម្មកម្ពុជា ភាគច្រើនមានលក្ខណៈជាកសិកម្មខ្នាតតូច៖ កសិករជនបទប្រមាណ ៨៤% មានដីកសិកម្មតិចជាង ១ហិកតា (World Bank 2005, 2009a)។ វិស័យកសិកម្មនៅកម្ពុជាមានសក្ដានុពលខ្លាំង ហើយកំណើនផលិតភាព អាចជំរុញដល់ផលិតកម្មប្រកបដោយនិរន្តរភាព ជាពិសេសការងារ និងចំណូលរបស់អ្នកពឹងផ្អែកខ្លាំងលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត (Theng & Koy 2011) ដូច្នេះការលើកកម្ពស់សហគ្រាសផ្អែកលើកសិកម្មខ្នាតតូច អាចជួយបង្កើនកម្រិតជីវភាពនៅជនបទ និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីជួយទ្រទ្រង់ដល់ជីវភាព របស់អ្នកធ្វើកសិកម្មខ្នាតតូចទាំងនោះ រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់អាទិភាពដល់ការអភិវឌ្ឍកសិកម្ម ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ (RS) ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក (SAW) ដោយបានទទួលស្គាល់ និងលើកទឹកចិត្តអ្នកធ្វើកសិកម្មខ្នាតតូច និងអង្គការកសិករ (FOs) ដែលជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្រ (Chea 2010)។

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ច្បាស់ថា អង្គការកសិករជាគន្លឹះសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងកសិកម្មជនបទ ប៉ុន្តែនៅមានការសិក្សាតិចតួចណាស់ស្ដីពី ផលប៉ះពាល់នៃអង្គការកសិករទៅលើកម្រិតជីវភាពនៅជនបទ។ លើសពីនេះទៅទៀត នៅមិនទាន់មានការសិក្សាអ្វីសោះទេ ពីផលប៉ះពាល់នៃអង្គការកសិករទៅលើជីវភាពរបស់អ្នកធ្វើកសិកម្មខ្នាតតូចនៅកម្ពុជា កុំថាឡើយដល់ទៅ ផលប៉ះពាល់ផ្សេងៗគ្នានៃអង្គការកសិករ (FOs) ប្រភេទខុសៗគ្នានោះ។ ការយល់ដឹងកាន់តែប្រសើរ អំពីផលប៉ះពាល់នៃសមាជិកភាពនៅក្នុង FO ទៅលើកំណើនប្រាក់ចំណូល និងការកំណត់ពីអត្ថប្រយោជន៍ដែលសមាជិកអង្គការកសិករ (FO) ទទួលបាន និងបញ្ហាដែលអង្គការកសិករត្រូវប្រឈម នឹងជួយបង្កើនការយល់ដឹងអំពីវិស័យអង្គការកសិករនៅកម្ពុជា ជួយរៀបចំឡើងវិញនូវគោលនយោបាយបច្ចុប្បន្ន និងរកឃើញមធ្យោបាយផ្សេងៗដែលមានប្រសិទ្ធភាពល្អ និងអាចឆ្លើយតបបានកាន់តែច្រើន ដល់សេចក្ដីត្រូវការរបស់អង្គការកសិករ និងគាំទ្របានកាន់តែប្រសើរដល់អ្នកធ្វើកសិកម្មខ្នាតតូច ដើម្បីកាត់បន្ថយភាពក្រីក្រ។

ការសិក្សានេះ វាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករ (FOs) ទៅលើសន្តិសុខស្បៀងរបស់អ្នកក្រីក្រជនបទ ដោយមានគោលដៅជាក់លាក់៖ (១) ពិនិត្យពីតួនាទី ប្រតិបត្តិការ និងបញ្ហាប្រឈមរបស់ FOs ក្នុងការលើកកម្ពស់សន្តិសុខស្បៀងរបស់គ្រួសារ (២) វិភាគពីលក្ខណៈគ្រួសារដែលកំណត់នូវការចូលរួមក្នុងអង្គការកសិករ (FOs) (៣) វាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករ (FOs) ទៅលើសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់អ្នកក្រីក្រនៅជនបទ និង (៤) ផ្ដល់អនុសាសន៍ជាក់លាក់សម្រាប់ការកែប្រែក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាក់ទិននឹងអង្គការកសិករ។

## វិធីសាស្ត្រ

*ប្រភេទអង្គការកសិករ (FOs) និងទីតាំងនៃការសិក្សា៖* នៅកម្ពុជាមានអង្គការកសិករ (FO) ៥ប្រភេទផ្សេងគ្នា គឺក្រុមកសិករ (FG) សហគមន៍កសិករ (FC) សមាគមកសិករ (FA) សហករណ៍កសិកម្ម (AC) និង សហព័ន្ធកសិករ (FF)។ ក្នុងចំណោមអង្គការទាំងនេះ បណ្ដា FGs FAs និង ACs ដែលផ្ដោតលើការអភិវឌ្ឍវិស័យកសិកម្ម និងលើកកម្ពស់ជីវភាពជនបទឃើញមានច្រើនជាទូទៅជាងគេ។ ដូច្នេះ FOs ទាំង ៣ប្រភេទនេះត្រូវបានជ្រើសរើសមកធ្វើការសិក្សា។ ដើម្បីទទួលបានគំរូតាងតំណាងភូមិសាស្ត្របានល្អ ខេត្តចំនួន៤ ដែលមានដង់ស៊ីតេ FOs

---

[១] អត្ថបទនេះ រៀបរៀងដោយ លោក ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី ភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI។ លោក នូ កែវសុទ្ធា លោក កែវ សុជាតិ និងអ្នកស្រី ស៊ុំ ស្រីមុំ ជាអ្នកស្រាវជ្រាវ និងអ្នកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវ ក្នុងកម្មវិធីនេះដែរ។ អត្ថបទនេះសង្ខេបពីលទ្ធផលជាក់ស្ដែងនៃការសិក្សាអំពី *ការវាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករទៅលើសន្តិសុខស្បៀងរបស់ជនក្រីក្រនៅជនបទ* ដែលទទួលមូលនិធិពី ធនាគារពិភពលោក។

តារាង ១៖ ការប៉ាន់ស្មានដោយប្រើ Propensity Score ដើម្បីកំណត់ពីការចូលរួមក្នុង FO (ការប៉ាន់ស្មានបែប logit)

| អថេរ | FOs ទាំងអស់ | FG | FA | AC |
|---|---|---|---|---|
| | z | z | z | Z |
| អាយុមេគ្រួសារ | 2.58** | 0.76 | 2.50** | 2.71** |
| អាយុមេគ្រួសារលើកជាការ៉េ | -2.40** | -0.59 | -2.36** | -2.60** |
| ចំនួនឆ្នាំសិក្សារបស់មេគ្រួសារ | 0.93 | -0.57 | 1.17 | 1.59 |
| មេគ្រួសារចេះអាន និងសរសេរ | 1.54 | 1.52 | 0.79 | 1.62 |
| មេគ្រួសារជាបុរស | -2.96*** | -1.22 | -3.93*** | -0.89 |
| មេគ្រួសាររៀបការរួច | 1.46 | 0.59 | 2.78** | -0.74 |
| មេគ្រួសារអត់ការងារ | -3.19*** | -3.27*** | -1.78** | -0.61 |
| មេគ្រួសារមានប្រាក់ខែ | -0.36 | -0.82 | 0.72 | -0.04 |
| មេគ្រួសារជាកម្មករកសិកម្ម | -0.95 | -1.22 | 0.3 | -1.43 |
| ចំនួនឆ្នាំដែលមេគ្រួសាររស់នៅក្នុងភូមិ | -0.51 | -0.15 | -1.29 | -0.4 |
| ទំហំគ្រួសារ | -2.48** | -1.62* | -1.83** | -1.80** |
| ទំហំគ្រួសារលើកជាការ៉េ | 2.40** | 1.64* | 2.12** | 1.14 |
| អត្រាអ្នកក្នុងបន្ទុក (ធៀបនឹងមនុស្សអាយុពី ១៥-៦៥ឆ្នាំ) | 1.43 | 0.91 | 0.62 | 1.34 |
| ផ្ទៃដីដាំដុះគិតជាម៉ែត្រការ៉េ | -0.47 | -0.37 | 0.4 | -1.52 |
| ផ្ទៃដីដាំដុះគិតជាម៉ែត្រការ៉េលើកជាការ៉េ | 0.25 | 0.4 | -0.36 | 1.25 |
| កសិកម្មជាប្រភពចំបងនៃប្រាក់ចំណូលគ្រួសារ | 0.41 | -0.59 | 1.19 | 0.48 |
| គ្រួសារទទួលបានប្រាក់កម្ចីក្នុងរយៈ១២ខែចុងក្រោយ | 4.10*** | 3.50*** | 2.50** | 2.16** |
| សន្ទស្សន៍ទ្រព្យកសិកម្មគ្រួសារ | 1.92** | 1.51 | 0.97 | 1.74** |
| តម្លៃទ្រព្យសរុប | 1.87* | 0.64 | 0.11 | 3.74*** |
| តម្លៃទ្រព្យសរុបលើកជាការ៉េ | -2.09** | -1.05 | 0.05 | -3.27*** |
| តម្លៃផ្ទះ | 1.04 | -1.09 | 1.03 | 2.08** |
| តម្លៃផ្ទះលើកជាការ៉េ | -1.11 | 0.42 | -1.31 | -1.44 |
| ដីដាំដុះទទួលបានការស្រោចស្រព | 1.11 | 3.11*** | -0.92 | -0.95 |
| ខេត្តស្វាយរៀង | -0.28 | 2.04** | -1.83** | -2.48** |
| ខេត្តកំពត | -1.03 | -0.38 | -0.84 | -1.14 |
| ខេត្តបាត់ដំបង | 0.21 | 0.22 | 0.05 | 0.47 |
| ខេត្តកំពង់ធំ | - | - | - | - |
| ថេរ | -2.14 | -1.15 | -2.73 | -3.00 |
| Pseudo $R^2$ | 0.079 | 0.100 | 0.116 | 0.221 |
| ចំនួនសង្កេត | 695 | 510 | 470 | 445 |

*សម្គាល់: *, **, ***បង្ហាញពីភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងកម្រិត ១០% ៥% និង ១%។*

ខ្ពស់ជាងគេ ត្រូវបានជ្រើសរើស គឺមានខេត្ត បាត់ដំបង កំពង់ធំ ស្វាយរៀង និងកំពត។

*ការជ្រើសយកគំរូតាងគ្រួសារ៖* ដើម្បីទទួលបានគំរូតាងល្អ និងធានាឲ្យលទ្ធផលអាចទុកចិត្តបាន និងមានលក្ខណៈតំណាងល្អ FOs ចំនួន៥៤ ត្រូវបានជ្រើសរើសចេញពីខេត្តទាំង៤ ដោយប្រើវិធីជ្រើសដោយចៃដន្យសាមញ្ញ និងសមាមាត្រទៅនឹងចំនួនសរុបនៃ FO ប្រភេទនីមួយៗ នៅក្នុងខេត្តនីមួយៗ។ ចំនួន FGs FAs និង ACs ដែលត្រូវជ្រើសរើស គឺគណនាឡើងដោយផ្អែកតាមសមាមាត្រ ៥០:៣០:២០ ហើយតាមនេះគេទទួលបានគំរូតាងដែលមាន FGs ចំនួន ២៩ FAs ចំនួន ១៥ និង ACs ចំនួន ១០។ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃការចូលរួមក្នុង FOs គ្រួសារដែលមិនមែនជាសមាជិក FO មួយចំនួន ត្រូវបានជ្រើសរើសធ្វើជាក្រុមធៀប។ ការសិក្សាបានធ្វើសម្ភាសន៍ទាំងអស់ ៦៩៩គ្រួសារ ដែលបានជ្រើសរើសដោយចៃដន្យចេញពី ២៥ឃុំ ក្នុង ៤ខេត្តនេះដូចគ្នា[២] គឺមាន ៣៣០គ្រួសារជាសមាជិក FO និង ៣៦៩គ្រួសារមិនមែនជាសមាជិក FO។

២ សូមមើល Theng *et al.* (2011) ដើម្បីទទួលបានព័ត៌មានលម្អិតពីវិធីសាស្ត្រស្រាវជ្រាវ និងនីតិវិធីជ្រើសគំរូតាង។

តារាង ២៖ ផលប៉ះពាល់ជាមធ្យមទៅលើផលិតភាពស្រូវដោយប្រើវិធីសាស្ត្រ PSM

| អថេរ | Nearest neighbour matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs |
| **ប្រាក់ចំណូលពីស្រូវ /ហិកតា (0000 រៀល)** | | | | | | |
| គំរូតាង FOs ទាំងអស់ | 8.74 | 0.85 | 292/313 | 8.59 | 0.93 | 299/313 |
| - ក្រុមកសិករ | -4.00 | -0.29 | 129/313 | -1.22 | -0.1 | 132/313 |
| - សមាគមកសិករ | 23.34 | 1.36 | 82/313 | -0.95 | -0.07 | 91/313 |
| - សហករណ៍កសិកម្ម | 35.44 | 1.91** | 75/313 | 32.61 | 2.07** | 74/313 |
| **ប្រាក់ចំណេញពីស្រូវ /ក្នុង១ហិកតា (0000 រៀល)** | | | | | | |
| គំរូតាង FOs ទាំងអស់ | 8.23 | 0.41 | 292/313 | 12.94 | 0.75 | 299/313 |
| - ក្រុមកសិករ | -13.10 | -0.79 | 129/313 | -1.44 | -0.07 | 132/313 |
| - សមាគមកសិករ | 6.07 | 0.23 | 82/313 | 0.37 | 0.01 | 91/313 |
| - សហករណ៍កសិកម្ម | 50.19 | 2.43** | 74/313 | 52.87 | 2.41** | 74/313 |

*សម្គាល់: *, **, *** បង្ហាញពីភាពខុសគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងកម្រិត ១០% ៥% និង ១%។*

*ការប៉ាន់ស្មានពីផលប៉ះពាល់៖* ដើម្បីកំណត់ពីផលប៉ះពាល់នៃការចូលរួមក្នុង FOs ទៅលើសន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រជនបទ ការសិក្សាបានយកផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារ មកធ្វើជាតំណាង។ ផលិតផល និងចំណាយសរុបនៃការធ្វើស្រែ និងចិញ្ចឹមសត្វ ក៏បានយកមកប្រើដើម្បីប៉ាន់ស្មានពីលទ្ធផល ចំពោះគ្រួសារដែលបានទទួលអត្ថប្រយោជន៍ពីការចូលរួមក្នុង FO។ វិធីសាស្ត្រ Propensity score matching (PSM) បានយកមកប្រើដើម្បីធ្វើការប៉ាន់ស្មានជាក់ស្តែងពីផលប៉ះពាល់នៃសមាជិកភាពក្នុង FO ទៅលើផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារ (Caliendo & Kopeinig 2008)។

## លទ្ធផល និងការពិភាក្សា[៣]

### លក្ខណៈនៃការចូលរួមក្នុង FOs

ការវិភាគជាក់ស្តែងលើទិន្នន័យអង្កេត បង្ហាញថា កត្តាប៉ះពាល់ដល់ការចូលរួមក្នុង FO មានភាពខុសប្លែកគ្នារវាងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង (FGs, FAs, ACs) (តារាង ១)។ អាយុមេគ្រួសារ មានឥទ្ធិពលវិជ្ជមានគួរកត់សំគាល់លើការចូលរួមក្នុង FOs ប៉ុន្តែមេគ្រួសារមានអាយុលើសពី ៥៦ឆ្នាំ មិនសូវចូលជាសមាជិក FOs ក្នុងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង FA និង AC ទេ ហើយអាយុរបស់មេគ្រួសារ ក៏មិនមែនជាកត្តាកំណត់សំខាន់នៃការចូលរួមក្នុងអនុគំរូតាង FG ដែរ។ ទំនាក់ទំនងអវិជ្ជមានគួរកត់សំគាល់រវាង មេគ្រួសារជាបុរស និងការចូលរួមក្នុង FOs បង្ហាញថា គ្រួសារមានមេគ្រួសារជានារី ទំនងជាចូលរួមក្នុងគំរូតាង FOs ទាំងអស់ និង អនុគំរូតាង FA ច្រើនជាងគ្រួសារមានមេគ្រួសារជាបុរស ប៉ុន្តែសម្រាប់អនុគំរូតាង FGs និង ACs វាមិនដូច្នោះទេ។ ភាពអត់ការងារធ្វើរបស់មេគ្រួសារ និងទំហំគ្រួសារ មានផលប៉ះពាល់អវិជ្ជមានគួរកត់សំគាល់លើការចូលរួមក្នុង FOs ប៉ុន្តែការទទួលបានឥណទាន ជាកត្តាវិជ្ជមានចម្បងកំណត់ពីនិន្នាការនៃការចូលរួមក្នុងគំរូតាង Fos ទាំងអស់ និងអនុគំរូតាង ហើយលទ្ធផលស្រាវជ្រាវនេះមានលក្ខណៈស្រដៀងគ្នានឹងលទ្ធផលរបស់ Davis *et al.* (2010), Couturier *et al.* (2006) and Chea (2010)។

គ្រួសារដែលមានទ្រព្យកសិកម្មមានផលិតភាព ច្រើនតែចូលរួមក្នុង FOs ក្នុងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង AC (Bernard & Sphienlman 2009)។ ទំហំដីមិនមែនជាសូចនាករសំខាន់នៃការចូលរួមក្នុង FOs ទេ។ សុខមាលភាពរបស់គ្រួសារមានទំនាក់ទំនងវិជ្ជមានជាមួយការចូលរួមក្នុង FOs តែទំនាក់ទំនងនេះ បែរជាមានផលប៉ះពាល់អវិជ្ជមានទៅលើការចូលរួមនៅពេលគ្រួសារមានទ្រព្យសម្បត្តិសរុបឡើងដល់ ឬលើសពី ១៣,៦ លានរៀល។ ដូច្នេះកសិករមានមូលធនផលិតកម្មកាន់តែច្រើន មិនសូវក្លាយជាសមាជិក FOs ក្នុង គំរូតាង FOs ទាំងអស់ និង អនុគំរូតាង AC នោះទេ។ ការអប់រំរបស់មេគ្រួសារក៏មិនមែនជាកត្តាកំណត់សំខាន់នៃការចូលរួម សម្រាប់អនុគំរូតាងទាំងអស់ដែរ ដោយគ្រួសារនៅជនបទតែងទៅចូលរួមក្នុង FOs ដោយមិនគិតពីកម្រិតនៃមូលធនមនុស្សនោះទេ (តារាង ១)។

### ផលប៉ះពាល់នៃការចូលរួមក្នុង FO លើជីវភាពរស់នៅ

ផលប៉ះពាល់នៃការចូលរួមក្នុង FO លើចំណូល និងប្រាក់ចំណេញពីផលិតកម្មស្រូវ និងសត្វចិញ្ចឹម ត្រូវបានប៉ាន់ស្មាន

៣ ទាំងវិធីសាស្ត្របែបគុណភាព និងបរិមាណ បានយកមកប្រើដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃ FOs ទៅលើសន្តិសុខស្បៀងរបស់អ្នកក្រនៅជនបទកម្ពុជា ប៉ុន្តែក្នុងអត្ថបទនេះមានបង្ហាញតែព័ត៌មានបែបបរិមាណប៉ុណ្ណោះ។

តារាង ៣៖ ផលប៉ះពាល់ជាមធ្យមលើផលិតភាពសត្វចិញ្ចឹមដោយប្រើប្រាស់វិធីសាស្ត្រ PSM

| អថេរ | Nearest neighbour matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs |
| **ប្រាក់ចំណូលពីសត្វចិញ្ចឹម** | | | | | | |
| គំរូតាង FOs ទាំងអស់ | 84.30 | 1.48 | 275/297 | 90.33 | 1.79 * | 288/297 |
| - ក្រុមកសិករ | -27.86 | -0.54 | 126/297 | -30.50 | -0.77 | 125/297 |
| - សមាគមកសិករ | 190.14 | 1.44 | 82/297 | 200.92 | 1.76 * | 89/297 |
| - សហករណ៍កសិកម្ម | -17.68 | -0.17 | 69/297 | 150.99 | 1.72 * | 70/297 |
| **ប្រាក់ចំណេញពីសត្វចិញ្ចឹម** | | | | | | |
| គំរូតាង FOs ទាំងអស់ | 41.79 | 0.95 | 275/297 | 55.59 | 1.46 | 288/297 |
| - ក្រុមកសិករ | -12.15 | -0.25 | 123/297 | -18.56 | -0.51 | 125/297 |
| - សមាគមកសិករ | 36.80 | 0.44 | 86/297 | 116.56 | 1.65 * | 89/297 |
| - សហករណ៍កសិកម្ម | -72.51 | -0.84 | 69/297 | 109.16 | 1.67 * | 70/297 |

*សម្គាល់: *, **, *** បង្ហាញពីភាពខុសប្លែកគួរកត់សំគាល់ខាងស្ថិតិ នៅកម្រិត ១០% ៥% និង ១%។*

ជាក់ស្ដែង ដោយប្រើគំរូតាង FOs ទាំងអស់ និង អនុគំរូតាងនានា ដើម្បីកំណត់ថា FO ប្រភេទណា មានផលប៉ះពាល់ខ្លាំងទៅលើគ្រួសារជាសមាជិក។ បន្ទាប់ពីធ្វើឲ្យមានតុល្យភាពរវាងគ្រួសារជាសមាជិក និងមិនមែនជាសមាជិក FO ដោយប្រើវិធីសាស្ត្រ PSM លទ្ធផលជាក់ស្ដែងបង្ហាញថា ក្នុងគំរូតាង FOs ទាំងអស់ ទោះបីសមាជិក FO មានប្រាក់ចំណូល និងប្រាក់ចំណេញខ្ពស់ជាងគ្រួសារមិនមែនសមាជិក FO ក្ដី ក៏ការចូលរួមក្នុង FO (ពោលគឺ សម្រាប់សមាជិក FO) មិនបានជះឥទ្ធិពលអ្វីគួរកត់សំគាល់ទៅលើតម្លៃ (ប្រាក់ចំណូល) និងប្រាក់ចំណេញពីផលិតកម្មស្រូវនោះដែរ។ ប៉ុន្តែនៅកម្រិតអនុគំរូតាង ការចូលរួមក្នុង AC (ពោលគឺ សម្រាប់សមាជិក AC) មានផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់ទៅលើផលិតកម្មស្រូវ និងប្រាក់ចំណេញ។ ភាពខុសគ្នារវាងប្រាក់ចំណូលពីស្រូវជាមធ្យមរបស់សមាជិក AC និងគ្រួសារមិនមែនជាសមាជិកអង្គការកសិករ មានប្រហែល ៣២៦.១០០រៀល (៨០,៣២ដុល្លារ) ក្នុង១ហិកតា ហើយប្រាក់ចំណេញទទួលបានពីស្រូវ មានប្រមាណ ៥២៨.៧០០រៀល (១៣០,២២ដុល្លារ) ក្នុងមួយហិកតា ដែលបង្កប់ន័យថា គ្រួសារជាសមាជិកសហករណ៍កសិកម្ម មានបច្ចេកទេសល្អ និងចំណាយមានប្រសិទ្ធភាពខ្ពស់ជាង គ្រួសារមិនមែនជាសមាជិកអង្គការកសិករ (តារាង ២)[៤]។ លទ្ធផលនេះស្របគ្នានឹងការសិក្សារបស់ Bratton (1986), Bachke (2010), and Davis *et al.* (2010)។

ផលប៉ះពាល់នៃការចូលរួមក្នុង FO ទៅលើប្រាក់ចំណូល និងប្រាក់ចំណេញបានពីសត្វចិញ្ចឹមក្នុង ១គ្រួសារ មានបង្ហាញក្នុង តារាង ៣។ ការប៉ាន់ស្មាននេះបង្ហាញថា ការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់ខាងស្ថិតិ ទៅលើប្រាក់ចំណូល (តែមិនមែនប្រាក់ចំណេញទេ) ដែលបានពីផលិតកម្មសត្វចិញ្ចឹមក្នុងគំរូតាងអង្គការកសិករទាំងអស់។ ជាមធ្យមប្រាក់ចំណូលរបស់សមាជិកអង្គការកសិករ ពីផលិតកម្មសត្វចិញ្ចឹម មានប្រមាណ ៩០៣.៣០០រៀល (២២២ដុល្លារ) ក្នុងមួយឆ្នាំ ខ្ពស់ជាងប្រាក់ចំណូលគ្រួសារមិនមែនជាសមាជិក FOs ហើយភាពខុសគ្នានេះ មានលក្ខណៈគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១០%។ ទាក់ទិននឹងអនុគំរូតាង ផលប៉ះពាល់មានលក្ខណៈវិជ្ជមានគួរកត់សំគាល់ខាងស្ថិតិទៅលើគ្រួសារសមាជិក FA និងសហករណ៍កសិកម្ម តែមិនមែនលើប្រាក់ចំណូល និងប្រាក់ចំណេញពីផលិតកម្មសត្វចិញ្ចឹមរបស់គ្រួសារសមាជិក FG នោះទេ។ ជាមធ្យម គ្រួសារចូលរួមក្នុង FAs និង ACs រកប្រាក់ចំណូលពីសត្វចិញ្ចឹមបាន ២០០.៩២០រៀល (៥០ដុល្លារ) និង ១៥០.៩៩០រៀល (៣៧ដុល្លារ) រៀងគ្នា ហើយវាមានកម្រិតខ្ពស់ជាងគ្រួសារមិនមែនជាសមាជិក និងមានលក្ខណៈគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១០%។

ផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់នៃ ការចូលរួមក្នុងអង្គការកសិករ ទៅលើតម្លៃផលិតកម្មស្រូវ និងសត្វចិញ្ចឹម ភាគច្រើនកើតឡើងផ្ទាល់ពី ការប្រើប្រាស់បច្ចេកទេសកសិកម្មកាន់តែល្អ ដែលផ្ដល់ដោយបណ្ដាទីភ្នាក់ងារគាំទ្រ។ លទ្ធផលអង្កេតបានបញ្ជាក់គាំទ្រថា គ្រួសារសមាជិកអង្គការកសិករ ទទួលបានសេវាបច្ចេកទេសកសិកម្ម សម្រាប់លើកកម្ពស់ផលិតភាពដំណាំ និងសត្វចិញ្ចឹមបានច្រើនជាង គ្រួសារមិនមែនជាសមាជិក។ ទោះយ៉ាងនេះក្ដី ផលប៉ះពាល់ខ្លាំងទៅលើផលិតភាពស្រូវ និងសត្វចិញ្ចឹមនេះ មិនអាចចាត់ទុកថា បានមកពីសកម្មភាពរួមទាក់ទិននឹងការមានទីផ្សារសម្រាប់ទិញធាតុចូល ឬលក់ផលិតផលនោះទេ។ ដោយសារ សកម្មភាពរួមរបស់សមាជិកអង្គការកសិករមិនសូវមានប្រសិទ្ធភាព ដូច្នេះសមាជិកអង្គការកសិករភាគច្រើន

---
៤ ការពិភាក្សាពីលទ្ធផលនេះ ផ្ដោតលើវិធីសាស្ត្រ Kernel matching algorithm។

ទិញធាតុចូល (៧៦%) និងលក់ផលិតផល (៨១%) ជាលក្ខណៈបុគ្គល ហើយត្រូវបង់ថ្លៃ និងលក់បានថ្លៃ ប្រហាក់ប្រហែលគ្នានឹងគ្រួសារមិនមែនសមាជិកដែរ[៥]។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះសន្និដ្ឋានថា អង្គការកសិករ (FOs) ជាយន្តការអភិវឌ្ឍន៍ជនបទដ៏ល្អមួយ សម្រាប់ពង្រឹងសន្តិសុខស្បៀងគ្រួសារនៅជនបទ តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម។ ការចូលរួមក្នុង AC មានផលប៉ះពាល់វិជ្ជមានទៅលើសន្តិសុខស្បៀងគ្រួសារជនបទ តាមរយៈការលើកកម្ពស់ផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម ហើយការចូលរួមក្នុង FA តែមួយមុខ ជះឥទ្ធិពលវិជ្ជមានទៅលើផលិតកម្មសត្វចិញ្ចឹម។ ផលប៉ះពាល់ទាំងនេះ ជាទូទៅអាចចាត់ថា កើតឡើងដោយសារការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដោយបណ្តាទីភ្នាក់ងារជួយគាំទ្រ។ ប៉ុន្តែ FOs នៅកម្ពុជា មិនបានលើកកម្ពស់លទ្ធភាពមានទីផ្សាររបស់សមាជិកនានាទេ ពីព្រោះការទិញធាតុចូល និងការលក់ផលិតផលកសិកម្ម ច្រើនធ្វើឡើងជាលក្ខណៈបុគ្គល ដូច្នេះថ្លៃដែលត្រូវចំណាយ ឬតម្លៃដែលអាចលក់បានដោយសមាជិកអង្គការកសិករ គឺវាប្រហាក់ប្រហែលគ្នានឹងគ្រួសារដែលមិនមែនជាសមាជិកដែរ។

ដើម្បីពង្រឹង FOs ឲ្យក្លាយជាឧបករណ៍ដ៏សក្តិសិទ្ធិជួយលើកកម្ពស់ជីវភាពនៅជនបទកម្ពុជា គេត្រូវដោះស្រាយបញ្ហាបារម្ភមួយចំនួនដែលការសិក្សាបានរកឃើញ។ ការបណ្តុះបណ្តាលពីរបៀបធ្វើកសិកម្មឲ្យកាន់តែល្អប្រសើរ គួរតែផ្តល់ជាបន្តបន្ទាប់ទៅដល់ FOs ដើម្បីកែលម្អផលិតភាព។ ក្រៅពីនេះ គោលនយោបាយរដ្ឋាភិបាលក្នុងការផ្តល់ឲ្យ FOs នូវប្រាក់កម្ចីមានរយៈពេលវែង និងការប្រាក់ទាប (ប្រមាណ១០% ក្នុង១ឆ្នាំ និងរយៈពេលបង្វិលសងយ៉ាងតិច ២ឆ្នាំ) អាចជួយឲ្យសមាជិក FOs បង្កើនវិនិយោគក្នុងផលិតកម្មកសិកម្ម។ ម្យ៉ាងទៀតដើម្បីឲ្យការចូលរួមក្នុង FOs ហុចផលបានកាន់តែច្រើនក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពនៅជនបទ អ្នកពាក់ព័ន្ធនានា ជាពិសេសរាជរដ្ឋាភិបាល គួរជួយគាំទ្រជាធាតុចូលបំពេញបន្ថែមមួយចំនួន និងលទ្ធភាពមានទីផ្សារកាន់តែល្អ។ ការធ្វើកសិកម្មតាមកិច្ចសន្យា អាចជាយន្តការដ៏ល្អសម្រាប់ឲ្យ FOs រកបានការចំណាយលើធាតុចូលកម្រិតទាប និងការធានាថ្លៃលើទីផ្សារ។ ដើម្បីធ្វើឲ្យអង្គការកសិករ (FOs) ទាំងអស់នៅកម្ពុជា មាននិរន្តរភាព ជំនួយឧបត្ថម្ភពីខាងក្រៅ (បច្ចេកទេស និងធនធាន) គួរផ្តល់ឲ្យដោយមានផែនការរយៈពេលវែង ដើម្បីអនុញ្ញាតឲ្យអង្គការកសិករ មានពេលរៀនសូត្រធ្វើការងារឲ្យបានសក្តិសិទ្ធិ និងមានប្រសិទ្ធភាព មុនពេលត្រូវដំណើរការដោយឯករាជ្យ។

៥ សូមមើល Theng *et al.* (2011) សម្រាប់លទ្ធផលអង្កេតស្តីពីការទទួលបានសេវាកម្មបណ្តុះបណ្តាល និងការលក់ផលិតផល។

## ឯកសារយោង


Bachke, M.E. (2010), *Do Farmers' Organizations Enhance The Welfare of Small-Scale Farmers?* Working Paper (Aas, Norway: Norwegian University of Life Sciences)

Barham, J. & C. Chitemi (2009), "Collective Action Initiatives to Improve Marketing Performance: Lesson Learn From Farmer Groups in Tanzania," *Food Policy*, Vol. 34, pp. 53-59

Bernard, T. & D. J. Spielman (2009), "Reaching the Poor through Rural Producer Organization? A Study of Agricultural Marketing Cooperatives in Ethiopia", *Food Policy*, Vol. 34, pp. 60-69

Bingen, J., A. Serrano & J. Howard (2003), "Linking Farmer to Market: Different Approaches to Human Capital Development", *Food Policy*, Vol. 28, pp. 405-419

Bratton, Michael (1986), "Farmer Organisations and Food Production", *World Development*, 14 (3), pp. 367-384

Caliendo, M. & S. Kopeinig (2008), "Some Practical Guidance for the Implementation of Propensity Score Matching", *Journal of Economic Surveys*, Vol. 22, No.1, pp. 31-72

Chea, S. (2010), "Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension"(Cambodia: MAFF, sponsored by IFAD and FAO)

Chirwa, E., A. Dorward, R. Kachule, I. Kumwenda, J. Kydd, N. Poole, C. Poulton & M. Stockbridge (2005), "Walking Tightropes: Supporting Farmer Organisations for Market Access", Natural Resource Perspective, Number 99 (London: ODI)

Couturier, J., S.O. Savun, & P. Ham (2006), "Inventory of Farmer Organisations in Cambodia". Draft prepared for Office if Farmer Organisation, Department of Agricultural Extension, Ministry of Agriculture, Forestry and Fisheries, Cambodia

Davis, K., Ephraim Nkony, E. Kato, D.A. Mekonnen, M. Orendo, R. Miiro & J. Nkuba (2010), "Impact of Farmer Field Schools on Agricultural Productivity and Productivity and Poverty in East Africa", IFPRI Discussion Paper 00992 (Washington, DC: IFPRI)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperative in Cambodia", *Cambodia Development Review* (Phnom Penh: CDRI)

Paula Savanti & Elisabeth Sadoulet (2008), Agriculture's Special Powers in Reducing Poverty. *Special Report: World Bank Institute*, World Bank

Theng V. & Koy R. (2011), "Review of Agricultural Policy and Policy Research", policy discussion paper (Phnom Penh: CDRI)

Theng Vuthy, Nou Keosothea, Keo Socheat, Sum Sreymom & Khiev Pirom (2011), *Do Farmer Organisations Help to Improve Food Security of the Rural Poor in Cambodia: Case Studies of Farmer Groups, Farmer Associations and Agricultural Cooperatives*, CDRI Working Paper Series (forthcoming) (Phnom Penh: CDRI)

World Bank (2005), "Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction" (Washington DC: World Bank)

World Bank (2009), "Poverty Profile and Trend in Cambodia: Findings from the 2007 CSES" (Phnom Penh: World Bank)